# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩.សសរ

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិ

## អាហារូបករណ៍ នៃមូលនិធិព្រះអាទិត្យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១**: បង្កើតគណៈកម្មាធិការជាតិអាហារូបករណ៍ នៃមូលនិធិព្រះអាទិត្យ ដែលមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១- សម្តេច | ហ៊ុន សែន | នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា | ប្រធានកិត្តិយស |
| ២- ឯកឧត្តម | សុខ អាន | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ៣- ឯកឧត្តម | អ៊ឹម សិទ្ធី | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា | អនុប្រធាន |
| ៤- ឯកឧត្តម | ស៊ាន បូរ៉ាត | ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា | អនុប្រធាន |
| ៥- បណ្ឌិត | ជា ចាន់ដេត | ទីប្រឹក្សាឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អគ្គលេខាធិការ |
| ៦- ឯកឧត្តម | ពេជ សោភ័ន | អគ្គនាយកឧត្តមសិក្សា បច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងអប់រំ យុវជន និង កីឡា | សមាជិក |
| ៧- លោក | ជា អឿន | អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុនៃក្រសួងអប់រំយុវជននិងកីឡា | សមាជិក |
| ៨- លោក | ឃឹម ពិសិដ្ឋ | ប្រធាននាយកដ្ឋានអប់រំ នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩- លោក | ហ្វ៊ីន លីមស៊ុំ | ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅនៃក្រសួងអប់រំ យុវជន និង កីឡា | សមាជិក |
| ១០- អ្នកស្រី | កាន្ទ នារី | អនុប្រធាននាយកដ្ឋានទំនាក់ទំនងវប្បធម៌ និង អាហារូបករណ៍ នៃក្រសួងអប់រំ យុវជន និង កីឡា | សមាជិក |

**ប្រការ ២:** គណៈកម្មាធិការជាតិនេះ មានភារកិច្ចទទួលខុសត្រូវ និង គ្រប់គ្រងមូលនិធិព្រះអាទិត្យអោយមានតម្លាភាព ។

**ប្រការ ៣:** គណៈកម្មាធិការជាតិនេះ មានភារកិច្ចជ្រើសរើសសិស្សពូកែជំរើសជាតិ ផ្នែកអក្សរសិល្ប៍, គណិតវិទ្យា និងរូបវិទ្យា ដើម្បីបញ្ជូនអោយទៅសិក្សាបន្តនៅប្រទេសជប៉ុន ចាប់ពីឆ្នាំសិក្សា២០០១-២០០២ នេះតទៅ ។

**ប្រការ ៤:** ដើម្បីរៀបចំការងារនេះអោយបានល្អ និង មានភាពរលូននោះ គណៈកម្មាធិការជាតិនេះ ត្រូវសហការ និងទំនាក់ទំនងជាមួយភាគីជប៉ុនដែលជាម្ចាស់អំណោយ ជាប្រចាំ ព្រមទាំងធ្វើការអំពាវនាវដល់សប្បុរសជនកម្ពុជា អោយចូលរួមជាវិភាគទានក្នុងមូលនិធិព្រះអាទិត្យអោយបានកាន់តែច្រើន ដើម្បីជាគុណប្រយោជន៍ដល់កូនខ្មែរ ។

**ប្រការ ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចមានរាយនាមក្នុងប្រការ ១ ត្រូវអនុវត្តនូវសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០២*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ